# ការអនុវត្តន៍ល្អ
## ច្រកទ្វារចូលរោងចក្រ

រោងចក្រ កាន់តែប្រសើរ នៅកម្ពុជា

ដំបូងភ្ញៀវ និងកម្មករមើលឃើញច្រកទ្វារចូលរោងចក្រ ដែលច្រកទ្វារនេះ បង្ហាញពីសញ្ញាជាវិជ្ជមានពីគុណភាព និងការងាររបស់រោងចក្រ ។ ច្រកទ្វារចូលដែលមានសណ្តាប់ធ្នាប់ល្អ និងស្អាត ធ្វើអោយមានចំណាប់អារម្មណ៍វិជ្ជមានតំបូងគេបង្អស់ រីឯច្រកចូលដែលមានភាពក្រខ្វក់ និងគ្មានសណ្តាប់ធ្នាប់ឆ្លុះបញ្ចាំងអោយឃើញពីភាពអន់ខ្សោយរបស់រោងចក្រ ។ រោងចក្រដែលមានច្រកទ្វារចូលស្អាត មានសណ្តាប់ធ្នាប់ល្អ និងមានសុវត្ថិភាព បង្ហាញអោយឃើញពីការប្តេជ្ញាចិត្តលើគុណភាព ផលិតភាព និងល័ក្ខខ័ណ្ឌការងារល្អប្រសើរ ។

### ការអនុវត្តន៍ល្អសំរាប់ច្រកទ្វារចូលរោងចក្រ

បង្ហាញឈ្មោះរោងចក្រ ឡូហ្គោ អោយបានច្បាស់ (រូបភាពទី១) ។

ប្រើប្រាស់ផ្លាកសញ្ញាអោយបានច្បាស់ ដើម្បីជួយបង្ហាញដល់ភ្ញៀវ និងកម្មករដែលដើរមើលជុំវិញរោងចក្រ ។ ទាំងនេះក៏បង្ហាញផងដែរថា រោងចក្រមានការរៀបចំបានល្អ (រូបភាពទី២) ។

ធានាយ៉ាងណាអោយច្រកទ្វារចូលទៅកាន់រោងចក្រមានភាពស្អាត និងមានសណ្តាប់ធ្នាប់ល្អ (រូបភាពទី៣) ។

លាបពណ៌ឡើងវិញលើពណ៌ចាស់ ឬសំណង់ដែលហើរពណ៌ ។

ធានាថាអ្នកយាមត្រូវបានទទួលការបណ្តុះបណ្តាលពីនីតិវិធីត្រឹមត្រូវ ក្នុងការអនុញ្ញាតិអោយភ្ញៀវ និងកម្មករចូលរោងចក្រ ។

ប្រកាសប្រាប់កម្មករពីការរំពឹងទុករបស់រោងចក្រ ទាក់ទងទៅនឹងអកប្បកិរិយានៅជុំវិញច្រកទ្វាររោងចក្រ ។



រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ បញ្ជូនសារស្តីពីសញ្ញាជាវិជ្ជមានដល់ភ្ញៀវ អ្នកបញ្ជាទិញ និងកម្មករ
- ✓ បង្ហាញពីអកប្បកិរិយា និងការទទួលខុសត្រូវ និងការយកចិត្តទុកដាក់យ៉ាងម៉ត់ចត់
- ✓ បង្ហាញអោយដឹងថា ក្រុមហ៊ុនអោយតំលៃទៅលើផលិតភាព និងល័ក្ខខ័ណ្ឌការងារល្អ

### តាមរបៀបណា:

- ✓ ពិនិត្យឡើងវិញពីគុណភាពច្រកទ្វារចូលរោងចក្រ ដោយសួរទៅកាន់ភ្ញៀវដែលមកទស្សនកិច្ចរោងចក្រ ថាតើគេងាយស្រួលរក ហើយគេមានអារម្មណ៍យ៉ាងណាមកលើច្រកទ្វារចូលរោងចក្រ
- ✓ ធានាថា ផ្លាកសញ្ញាមានភាពច្បាស់ និងងាយស្រួលអាន
- ✓ បណ្តុះបណ្តាលដល់អ្នកយាមទ្វារស្តីពីរបៀបស្វាគមន៍ និងមានអកប្បកិរិយាជាមួយភ្ញៀវដែលមកទស្សនកិច្ចរោងចក្រ
- ✓ បំពាក់ផ្លាកសញ្ញាអោយបានសមរម្យ ឬផ្លាស់ប្តូរថ្មី និងនៅមានប្រសិទ្ធិភាពក្នុងការប្រើប្រាស់
- ✓ លាបពណ៌ឡើងវិញលើពណ៌ដែលចាស់

### តំលៃ:

$

$ តំលៃទាប

$$ តំលៃមធ្យម

$$$ តំលៃខ្ពស់